# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ២

នាសប្តាហ៍នេះ បានបង្ហាញពីការបើកសវនាការលើភស្តុតាងក្នុងការជំនុំជម្រះក្តីលើកទី២ លើសំណុំរឿង ០០២។ សវនាការនេះ ចាប់ផ្តើមបន្ទាប់ពីសវនាការបឋមដែលបានធ្វើកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ហើយនិងបន្ទាប់ពីក្រោយសេចក្តីប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណុំរឿង០០២ វគ្គទី១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កន្លងមក។ ជនរងគ្រោះ សហជនជាប់ចោទ និងអ្នកសង្កេតការណ៍តាមដានតុលាការជាច្រើន បានរង់ចាំការជំនុំជម្រះក្តីមួយនេះ ដោយផ្តោតការយកចិត្តទុកដាក់លើវិសាលភាពនៃឧក្រិដ្ឋកម្មនានាកាន់តែធំជាងមុន រួមមាន៖ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបទចោទប្រកាន់នានាដែលជនជាប់ចោទបានចូលរួមក្នុងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងអ្នកកាន់សាសនាអ៊ិស្លាមជនជាតិចាម ហើយនិងជនជាតិភាគតិចវៀតណាម។ ការជំនុំជម្រះនេះ ក៏មានសារសំខាន់ផងដែរក្នុងកម្រិតដែលត្រូវបានរំពឹងទុកថា នឹងគ្រប់ដណ្តប់នូវចំនួនដ៏ច្រើននៃទីតាំងឧក្រិដ្ឋកម្មនានា (រួមមាន៖ សហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខនានា នៅទូទាំងប្រទេស) ច្រើនជាងក្នុងវិសាលភាពនៃសំណុំរឿង០០១ និងសំណុំរឿង០០២ វគ្គទី១។

ទោះបីជាយ៉ាងនេះក្តី នៅថ្ងៃបើកសវនាការដែលគ្រោងនឹងប្រើប្រាស់ពេលវេលាដ៏យូរនេះ លទ្ធភាពនៃការបន្តពន្យារពេលវេលាបន្ថែម បានគ្រប់ដណ្តប់លើកិច្ចពិភាក្សាទាំងនៅក្នុង និងក្រៅសាលសវនាការ ដោយសារតែក្រុមមេធាវីការពារក្តីឲ្យសហជនជាប់ចោទទាំងពីរ បានធ្វើការប្រកាសអំពីគោលបំណងធ្វើពហិការសវនាការនេះ។ មេធាវីការពារក្តីឲ្យជនជាប់ចោទ មិនសប្បាយចិត្ត ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានជ្រើសចាប់

ផ្ដើមបើកសវនាការលើភស្តុតាងក្នុងសំណុំរឿង០០២ វគ្គទី២ នៅខណៈពេលដែលសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី កំពុងស្ថិតក្នុងដំណើរការធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២ វគ្គទី១ ជាមួយនឹងអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក។ មេធាវីការពារក្ដី បានធ្វើការតវ៉ាបន្ថែមថា ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង គួរតែដកខ្លួនចេញពីកិច្ចដំណើរការនីតិវិធីសវនាការនេះ ខណៈពេលដែលគណៈកម្មាធិការរដ្ឋបាលតុលាការសម្រេចលើសំណើរបស់មេធាវីការពារក្ដី ស្ដីពីបណ្ដឹងជំទាស់ចិត្តចៅក្រមចេញពីសំណុំរឿង០០២ វគ្គទី២នេះ។ ដោយសារតែសេចក្ដីប្រកាស និងការជំទាស់ទាំងនេះហើយ បានធ្វើឲ្យអង្គជំនុំជម្រះបន្តពន្យារពេលវេលាបើកសវនាការលើភស្តុតាង ហើយបានកំណត់ពេលបើកកិច្ចប្រជុំជាអសាធារណៈ ស្ដីពីការគ្រប់គ្រងសវនាការដែលនឹងត្រូវធ្វើឡើងនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤។

ផ្នែកទី២ នៃរបាយការណ៍នេះ រៀបរាប់ជាសង្ខេបស្ដីពីការដាក់សារណាសន្និដ្ឋានឯកសារចំនួនបីដែលបានប្ដឹងទៅតុលាការ មុននឹងការចាប់ផ្ដើមបើកសវនាការលើភស្តុតាងលើសំណុំរឿង០០២ វគ្គទី២។ ចំពោះផ្នែកទី៣ ផ្ដោតលើសេចក្ដីថ្លែងការណ៍បើកពីសំណាក់ភាគីនីមួយៗ ដែលបានធ្វើឡើងនៅក្នុងសវនាការកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ នេះ ព្រមទាំងសន្និសីទកាសែតជាបន្តបន្ទាប់ ដែលបានធ្វើឡើងដោយក្រុមមេធាវីការពារក្ដីដើម្បីធ្វើការបញ្ជាក់បន្ថែមពីការសម្រេចចិត្តរបស់ជនជាប់ចោទទាំងពីរ ក្នុងការធ្វើពហិការកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្នែកទី៤ ផ្ដោតលើវត្តមានរបស់ភាគីក្នុងសវនាការ ការគ្រប់គ្រងពេលវេលាសវនាការ និងបញ្ហានានាពាក់ព័ន្ធនឹងការគ្រប់គ្រងបន្ទប់សវនាការ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

* របាយការណ៍នេះត្រូវបានសរសេរដោយ ធីឡូ ហ្គតត៍ស្គលក៍ (Thilo Gottschalk), វ៉ាន់ណេសសា ហាហ្គើ (Vanessa Hager), ដានៀល ម៉ាតថេស៍ (Daniel Mattes), ពេជ្រ ចំរុង, តាយ លីណា, ស្ទេហ្វានី តេ (Stephanie Teh), ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl), និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ អង្គការ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាង មជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និង មជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដាសម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣ មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្ដួចផ្ដើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានា ក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។